អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស
## ថ្ងៃ១០ ធ្នូ ១៩៤៨ (ត) ។

www.hoksavann.org

ថ្ងៃទី១១ កុម្ភៈ ២០១២



លើកមុនយើងបានចុះផ្សាយមាត្រាខ្លះនៃធម្មនុញ្ញនៃអង្គការសហប្រជាជាតិស្តីអំពីសិទ្ធិមនុស្ស ព្រមទាំងបុព្វកថាខាងដើមនៃមាត្រាទាំងនោះ តទៅនេះយើងសូមចុះផ្សាយជាបន្ត ។ សូមបញ្ជាក់ថា បុព្វកថាដែលនាំឲ្យកើតសិទ្ធិមនុស្សនេះឡើង ដោយបន្ទាប់ពីបញ្ចប់សង្គ្រាមលោកលើកទីពីរមក ពិភពលោកបានសង្កេតឃើញថា ដំណោះស្រាយដោយយុទ្ធវិធីធ្វើសង្គ្រាមនឹងគ្នាបែបនេះ នាំឲ្យពិភពលោកវិនាសអន្តរាយ ទាំងសម្បត្តិធម្មជាតិទាំងជីវិតមនុស្ស ទើបបង្កើតឲ្យមានធម្មនុញ្ញនៃសិទ្ធិមនុស្សនេះឡើង ដើម្បីបង្ការកុំឲ្យកើតសង្គ្រាមផង ដើម្បីកុំឲ្យមានការឈ្លានពានគ្នាទៅវិញទៅមកផង ។

★ មាត្រា៤

គ្មានជនណាម្នាក់ត្រូវជាប់ក្នុងភាពជាខ្ញុំកញ្ជះ ឬក្នុងភាពជាអ្នកបំរើគេឡើយ ។ ហាមផ្តាច់មិនឲ្យមានទាសភាព និងរបរលក់ដូរមនុស្សសំរាប់ធ្វើជាខ្ញុំកញ្ជះគ្រប់បែបយ៉ាងទាំងអស់ ។

★ មាត្រា៥

គ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម ឬការធ្វើបាបយ៉ាងសាហាវឃោរឃៅ អមនុស្សធម៌ ឬថោកទាបឡើយ ។

★ មាត្រា៦

មនុស្សម្នាក់ៗមានសិទ្ធិឲ្យគេទទួលស្គាល់ខ្លួនជាបុគ្គលមួយរូបចំពោះមុខច្បាប់នៅគ្រប់ទីកន្លែង ។

★ មាត្រា៧

នៅចំពោះមុខច្បាប់ មនុស្សទាំងអស់មានភាពស្មើៗគ្នា ហើយមានសិទ្ធិដូចគ្នា ដើម្បីឲ្យច្បាប់ការពាររូបកាយខ្លួន ទប់ទល់កុំឲ្យមានការប្រកាន់ពណ៌សម្បុរ ពូជសាសន៍សព្វបែបយ៉ាង ដែលជាការរំលោភលើសេចក្តីប្រកាសនេះ ព្រមទាំងតទល់នឹងការបង្កហេតុនានា ដែលបណ្តាលឲ្យមានការប្រកាន់ពូជសាសន៍ ឬពណ៌សម្បុរ ។

★ មាត្រា៨

មនុស្សគ្រប់រូបមានសិទ្ធិប្តឹងទៅតុលាការអន្តរជាតិ ដែលមានសមត្ថភាពរកខុសត្រូវ អំពីអំពើទាំងឡាយណា ដែលរំលោភលើសិទ្ធិសំខាន់ៗរបស់ខ្លួន ហើយដែលមានចែងនៅក្នុងធម្មនុញ្ញ ឬនៅក្នុងច្បាប់ ។

★ មាត្រា៩

គ្មានបុគ្គលណាម្នាក់ត្រូវគេចាប់ចងឃុំឃាំង ឬនិរទេសខ្លួនដោយរំលោភបានឡើយ ។

★ មាត្រា១០

មនុស្សគ្រប់រូបមានសិទ្ធិពេញទីដូចគ្នាក្នុងការទាមទារទៅតុលាការមួយ ដែលមានឥស្សរភាពនិងភាពឥតលំអៀង ដើម្បីឲ្យកំណត់ដោយយុត្តិធម៌និងជាសាធារណៈ នូវសិទ្ធិនិងករណីយកិច្ចរបស់ខ្លួន ហើយនិងភាពសមហេតុសមផលនៃការចោទប្រកាន់ផ្នែកអាជ្ញាមកលើខ្លួន ។

★ មាត្រា១១

១- បុគ្គលណាដែលត្រូវគេចោទថា បានប្រព្រឹត្តបទល្មើសខាងបទអាជ្ញា មានសិទ្ធិសំអាងថាខ្លួនជាជនគ្មានទោស រហូតដល់មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ខ្លួនមានទោសទៅតាមគតិច្បាប់នៅក្នុងការជំនុំជំរះក្តីជាសាធារណៈ ដែលផ្តល់នូវការធានារ៉ាប់រងគ្រប់គ្រាន់សំរាប់បុគ្គលនោះធ្វើការការពារខ្លួន ។

២- គ្មានបុគ្គលណាម្នាក់ត្រូវគេកាត់ទោសឲ្យជាប់ពិរុទ្ធខាងបទអាជ្ញា ចំពោះអំពើឬការភ្លាំងភ្លាត់ដែលពុំមែនជាការល្មើស ខាងបទអាជ្ញាតាមក្របខណ្ឌច្បាប់របស់ជាតិឬអន្តរជាតិឡើយ ។ ដូចគ្នានេះដែរ គ្មានបុគ្គលណាម្នាក់ត្រូវគេកាត់ឲ្យទទួលទោសដែលបទល្មើសនេះបានប្រព្រឹត្តឡើយ ។

★ មាត្រា១២

គ្មានជនណាម្នាក់ត្រូវគេជ្រៀតជ្រែកដោយរំលោភ ក្នុងកិច្ចការផ្ទាល់ខ្លួន លំនៅដ្ឋាន គ្រួសារ សំបុត្រឆ្លើយឆ្លង ឬត្រូវគេប៉ះពាល់ដោយកិត្តិយសនិងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ ។ បុគ្គលគ្រប់រូបមានសិទ្ធិនិងមានច្បាប់ការពារខ្លួន ប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់ទាំងនេះ ។

★ មាត្រា១៣

១- បុគ្គលម្នាក់ៗមានសិទ្ធិធ្វើដំណើរដោយសេរី និងជ្រើសរើសលំនៅក្នុងបរិវេណរដ្ឋនីមួយៗ ។

២- បុគ្គលម្នាក់ៗមានសិទ្ធិចាកចេញពីគ្រប់ប្រទេស រួមទាំងប្រទេសរបស់ខ្លួនផង ហើយក៏មានសិទ្ធិវិលត្រឡប់មកមាតុប្រទេសរបស់ខ្លួនវិញដែរ ។

★ មាត្រា១៤

១- បុគ្គលម្នាក់ៗមានសិទ្ធិសុំនិងទទួលការជ្រកកោននៅប្រទេសដទៃ ក្នុងករណីដែលមានការធ្វើទុក្ខបុកម្នេញមកលើរូប

ខ្លួន ។

២- ប៉ុន្តែសិទ្ធិទាំងនេះ ពុំអាចលើកមកសំអាងបានទេ នៅក្នុងករណីណាដែលការធ្វើទុក្ខបុកម្នេញនោះកើតឡើងដោយបទល្មើស ដែលពុំមែនជាទោសនយោបាយ ឬដែលផ្ទុយពីគោលការណ៍និងបំណងនៃសហប្រជាជាតិ ។

យើងសូមបញ្ចប់មាត្រានេះត្រឹមនេះសិន ពេលក្រោយនឹងបន្តទៅទៀត ។ តាងការលើកយកមាត្រានៃធម្មនុញ្ញនៃអង្គការសហប្រជាជាតិយកមកបង្ហាញនេះបញ្ជាក់អត្ថន័យថា ជាច្បាប់បង្ការកុំឲ្យមនុស្សបៀតបៀនគ្នា តែត្រូវគោរពសិទ្ធិគ្នាទៅវិញទៅមក ។ ច្បាប់នេះស្របនឹងព្រះពុទ្ធសាសនាថា សេចក្ដីសុខចំរើនគ្រប់យ៉ាង កើតពីការមិនបៀតបៀនគ្នា ដោយកាន់ធម៌អហិង្សានាំឲ្យមានចិត្តស្ងប់មិនធ្វើអំពើបាប ។៚

* *

*